នស/រកត/០៣០៣/១១៦

# ព្រះរាជក្រឹត្យ

## ស្តីពី

## ការកំណត់មេណឌីយដ្ឋានសំបូរព្រៃគុក

*****

## យើង

## ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

## រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

## និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

## ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខនស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៦ ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបេតិកភ័ណ្ឌវប្បធម៌
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និង គ្រប់គ្រងធនធានធម្មជាតិ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ

ចងក្រងដោយអង្គការ EWMI-Cambodia ក្រោមគម្រោង "អភិរក្សសិទ្ធិលើដីធ្លីរបស់ពលរដ្ឋកម្ពុជា" ឧបត្ថម្ភដោយក្រសួងការបរទេសសហរដ្ឋអាមេរិក (04/09)

- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥ ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្ដីពីការបង្កើតក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងកិច្ចប្រជុំពេញអង្គថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០៣

## ត្រាស់បង្គាប់

### ជំពូកទី ១
### បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

កំណត់រមណីយដ្ឋានវប្បធម៌នៃប្រាសាទសំបូរព្រៃគុក ជារមណីយដ្ឋានការពារ ជាអតីតរាជធានីខ្មែរ ឈ្មោះថា ឥសានបុរៈ ក្នុងសតវត្សទី ៦-៧ ស្ថិតក្នុងស្រុកប្រាសាទសំបូរ ខេត្តកំពង់ធំ ។

**មាត្រា ២.-**

ការបង្កើតរមណីយដ្ឋាននេះមានគោលបំណង :

- អភិរក្សកេរដំណែលវប្បធម៌ ទាំងខាងបុរាណវិទ្យា ជាតិពន្ធុវិទ្យា ប្រវត្តិវិទ្យា និង លើកកំរិតតំលៃរមណីយដ្ឋានការពារឱ្យកាន់តែប្រសើរថែមទៀត
- អភិរក្ស ទេសភាពវប្បធម៌ និង អភិវឌ្ឍន៍តំបន់ទេសចរណ៍
- ការពារបរិស្ថាន ធម្មជាតិក្នុងតំបន់ តាមភូមិសាស្ត្រជាក់ស្ដែង ។

### ជំពូកទី ២
### ការកំណត់តំបន់

**មាត្រា ៣.-**

ត្រូវឱ្យត្រួតពិនិត្យរាល់ការអភិវឌ្ឍន៍រមណីយដ្ឋានការពារ ដោយគោរពតាមប្លង់កំណត់តំបន់ និង ការចាត់ចែងគ្រប់គ្រងតំបន់តាមចំណាត់ថ្នាក់តំបន់ដែលត្រូវការពារ ។

**មាត្រា ៤.-**

រមណីយដ្ឋានការពារប្រាសាទសំបូរព្រៃគុក ត្រូវចាត់ជា ៣ (បី)តំបន់ ផ្សេង១គ្នា ហើយត្រូវទទួលកំរិតការពារខុស១គ្នា :

១- តំបន់ស្នូល : ជាតំបន់ឧទ្យានប្រាសាទតូច-ធំ រួមទាំងសម្បត្តិវប្បធម៌ បុរាណវិទ្យា ព្រមទាំងវត្ថុតាងជាច្រើនទៀត ដែលមានរូបរាងនៅលើដី ឬកប់ក្នុងដី កំពុងស្រាវជ្រាវ ឬ ពុំទាន់ស្រាវជ្រាវ

រកឃើញ ដោយអ្នកបុរាណវិទ្យា ។ តំបន់នេះ **ហៅថា តំបន់ស្នូល** មានផ្ទៃក្រឡាសរុប ៣៨១.១១ហិកតា ។

តំបន់ស្នូលនេះ រួមមានតំបន់ ៣ ( បី ) : តំបន់ ក តំបន់ ខ តំបន់ គ ។

តំបន់ស្នូលត្រូវបានកំណត់ដូចខាងក្រោមនេះ :

តំបន់ ក : គឺជាតំបន់ដែលត្រូវកំណត់ស្ថិតក្នុងបរិវេណខ្សែបន្ទាត់និយាមការនៃចំណុច

$A_1$ ( 504939 ; 1423496 ) , $B_1$ ( 504521 ; 1423004 )
$C_1$ ( 504210 ; 1422372 ) , $D_1$ ( 504110 ; 1421913 )
$E_1$ ( 504262 ; 1421680 ) , $F_1$ ( 504580 ; 1421665 )
$G_1$ ( 504536 ; 1421428 ) , $H_1$ ( 504380 ; 1421102 )
$I_1$ ( 504391 ; 1420751 ) , $J_1$ ( 504462 ; 1420736 )
$K_1$ ( 504680 ; 1421187 ) , $L_1$ ( 504773 ; 1421665 )
$M_1$ ( 505094 ; 1421665 ) , $N_1$ ( 505224 ; 1421950 )
$T_1$ ( 506889 ; 1422109 ) , $S_1$ ( 506575 ; 1422575 )
$P_1$ ( 505365 ; 1422549 ) , $Q_1$ ( 505513 ; 1423064 )
$R_1$ ( 505376 ; 1423437 )

តំបន់ ខ : គឺជាតំបន់ដែលត្រូវកំណត់ស្ថិតក្នុងបរិវេណខ្សែបន្ទាត់និយាមការនៃចំណុច

$A_2$ ( 503211 ; 1425262 ) , $B_2$ ( 502904 ; 1424858 )
$C_2$ ( 503081 ; 1424185 ) , $D_2$ ( 504458 ; 1424288 )
$E_2$ ( 504613 ; 1425289 )

តំបន់ គ : គឺជាតំបន់ដែលត្រូវកំណត់ស្ថិតក្នុងបរិវេណខ្សែបន្ទាត់និយាមការនៃចំណុច

$U_3$ ( 502552 ; 1421073 ) , $V_3$ ( 502045 ; 1420962 )
$W_3$ ( 501557 ; 1423004 ) , $Z_3$ ( 503577 ; 1423256 )

តំបន់ ក ខ គ ជាតំបន់មានប្រាសាទសំខាន់ជាងគេក្នុងរមណីយដ្ឋានការពារ ហើយត្រូវទទួលកិច្ចការពារកំរិតខ្ពស់បំផុត ។

២- **តំបន់ទ្រនាប់** : ជាតំបន់ឧទ្យានបុរាណវត្ថុ ដែលមានបន្សល់ទុកនូវដានស្នាកស្នាម ឬ កប់ក្នុងដីរាក់ ឬជ្រៅ ពុំទាន់រុករកឃើញដោយអ្នកបុរាណវិទ្យា នៅតាមទីវាល ផ្ទៃដី ឬ ក្នុងភូមិ ឃុំ ក្រោមផ្ទះប្រជាពលរដ្ឋជាដើម ។ តំបន់នេះ **ហៅថាតំបន់ទ្រនាប់** មានផ្ទៃក្រឡា ២៩៨២.៤៥ហិកតា ។

តំបន់នេះស្ថិតនៅក្រៅបរិវេណនៃតំបន់ ក តំបន់ ខ និង តំបន់ គ នៃតំបន់ស្នូល ហើយស្ថិតក្នុងបរិវេណខ្សែបន្ទាត់និយាមការនៃចំណុច

A ( 502721 ; 1426711 ) , B ( 501633 ; 1425998 )
C ( 500537 ; 1423348 ) , D ( 501733 ; 1418978 )
E ( 504456 ; 1420172 ) , F ( 505480 ; 1420622 )
G ( 505567 ; 1421717 ) , H ( 508911 ; 1421701 )
I ( 508909 ; 1422487 ) , J ( 505583 ; 1424066 )

ចងក្រងដោយអង្គការ EWMI-Cambodia ក្រោមគម្រោង "អភិរក្សសិទ្ធិលើដីធ្លីរបស់ពលរដ្ឋកម្ពុជា" ឧបត្ថម្ភដោយក្រសួងការបរទេសសហរដ្ឋអាមេរិក (04/09)

K ( 505604 ; 1425246 )

តំបន់នេះសំបូរដោយសំណល់បុរាណវត្ថុ ដែលត្រូវការពារ ទប់ស្កាត់និងការប្រើប្រាស់ដីធ្លី និង ការអភិវឌ្ឍនមិនសមស្រប ។

៣- **តំបន់រណប :** ជាតំបន់អភិវឌ្ឍសេដ្ឋកិច្ច និង សង្គមកិច្ច ហៅថាតំបន់រណប ដោយរក្សាជីវភាព មុខរបរ អាជីវកម្ម តាមទំនៀមទំលាប់ប្រពៃណី ព្រមទាំងការរស់នៅរបស់ប្រជាពលរដ្ឋក្នុងតំបន់ ។ តំបន់នេះស្ថិតនៅក្រៅពីបរិវេណដែលមាននិយាមការចំណុច A B C D E F G H I J K ចម្ងាយ ១.៥០០ម៉ែត្រ ។

តំបន់នេះជាគោលដៅថែរក្សាបេតិកភ័ណ្ឌវប្បធម៌ និង ធម្មជាតិ តាមរយៈការចាត់ចែងវិធានការ ដើម្បីជំរុញការអភិវឌ្ឍឱ្យមានចិរភាព និង មានការវាយតំលៃហេតុប៉ះពាល់លើបរិស្ថាន ។

ប្លង់កំណត់តំបន់រមណីយដ្ឋានប្រាសាទសំបូរព្រៃគុក មានក្នុងឧបសម្ព័ន្ធនៃព្រះរាជក្រឹត្យនេះ ។

## ជំពូកទី ៣
## ការគ្រប់គ្រង ថែទាំ និង ការពារ

**មាត្រា ៥ .-**

ការអភិរក្សរាល់តំបន់នីមួយៗ សុទ្ធតែត្រូវបានគ្រប់គ្រង ថែទាំ និង ការពារ ស្របតាមទិសដៅ ចំណាត់ថ្នាក់តំបន់ដូចមានចែងក្នុងមាត្រា ៤ នៃព្រះរាជក្រឹត្យនេះ និង កំរិតនៃសារៈសំខាន់ដោយឡែកៗ ទាំងខាង បូរាណវិទ្យា ជាតិពន្ធុវិទ្យា ប្រវត្តិវិទ្យា បរិស្ថាន ធម្មជាតិ គោរពនូវសិទ្ធិជាម្ចាស់របស់ប្រជាពលរដ្ឋរស់នៅក្នុង តំបន់ទាំងមូល ខាងជីវភាពរស់នៅ និង លើកស្ទួយរមណីយដ្ឋានការពារឱ្យមានតំលៃកាន់តែខ្ពស់ឡើង ។

**មាត្រា ៦ .-**

ត្រូវអនុវត្តនូវនយោបាយរបស់ក្រុមប្រឹក្សាជាតិជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ ដើម្បីធានាការគ្រប់គ្រង ថែទាំ និងការពារ ដោយកំណត់ភាពម្ចាស់ការ ទទួលខុសត្រូវរបស់បណ្តាស្ថាប័នមានសមត្ថកិច្ច ដែលមានក្រសួង វប្បធម៌ និង វិចិត្រសិល្បៈ ទទួលអនុវត្តផ្ទាល់ ផ្អែកលើមាត្រា៥ នៃច្បាប់ស្តីពីកិច្ចការពារបេតិកភ័ណ្ឌវប្បធម៌ ដែលប្រកាសឱ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៦ ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ១៩៩៦ ។

បែបបទ និង នីតិវិធី នៃការគ្រប់គ្រង ថែទាំ និង ការពារ រមណីយដ្ឋានប្រាសាទសំបូរព្រៃគុកក្នុង បណ្តាមាត្រាខាងលើ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ៧ .-**

បរិវេណ និង រាល់សកម្មភាពរបស់តំបន់នីមួយៗនៃរមណីយដ្ឋានការពារប្រាសាទសំបូរព្រៃគុក អាចពិនិត្យ ឡើងវិញហើយកែប្រែបាន ដោយផ្អែកលើរាល់លទ្ធផល នៃការស្រាវជ្រាវរបស់អ្នកវិទ្យាសាស្ត្របុរាណវិទ្យា និងស្ថានភាព

ចងក្រងដោយអង្គការ EWMI-Cambodia ក្រោមគម្រោង "អភិរក្សសិទ្ធិលើដីធ្លីរបស់ពលរដ្ឋកម្ពុជា" ឧបត្ថម្ភដោយក្រសួងការបរទេសសហរដ្ឋអាមេរិក (04/09)

ជាក់ស្តែង ដើម្បីធានាដល់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមកិច្ច ការអភិរក្ស និងការគ្រប់គ្រងមួយប្រកបដោយនិរន្តរភាព ដូចមានចែងក្នុងមាត្រា ៤ ។

ការកែប្រែតំបន់ និង រាល់សកម្មភាពពាក់ព័ន្ធនិងរមណីយដ្ឋានប្រាសាទសំបូរព្រៃគុក ត្រូវកំណត់ដោយព្រះរាជក្រឹត្យតាមសំណើរបស់រាជរដ្ឋាភិបាល ។

## ជំពូកទី ៤
## អវសានប្បញ្ញត្តិ

**មាត្រា ៨ ..**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៩ ..**

សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខាតទៅ ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី១១ ខែមិថុនា ឆ្នាំ ២០០៣

**ព្រះហស្ថលេខា និង ព្រះរាជលញ្ឆករ**

នស/រកត.០៦.០៣.១២៤ **នរោត្តម សីហនុ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្ថលេខាព្រះមហាក្សត្រ
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**ហ៊ុន សែន**

លេខៈ ៩៧៦ ចល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ២០០៣
**អគ្គលេខាធិការរាជរដ្ឋាភិបាល**
**សុខ ចិន្តាសោភា** តាន់


1500m
K - 505804, 1426637
J - 505683, 1424066
G - 505567, 1421717
F - 506480, 1420621
E - 504405, 1420621
D - 501733, 1418978
C - 500637, 1422549
H - 508911, 1421170
1:35000